ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែសីហា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែសីហានេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៥៦៧ ៨២៣ហ.ត ស្មើនឹង៩៨,០៣% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែសីហា ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែសីហា ឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៥៨៥ ១០៨ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៨ ៨១៤ហ.ត ស្មើនឹង០,៣៤% និងដោយគ្រឿងយន្តចំនួន ២ ៥៧៦ ២៩៤ហ.ត ស្មើនឹង៩៩,៦៦% តិចជាងឆ្នាំមុន ១៦៦ ៩៤១ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១០ ០៨៧ហ.ត តិចជាងឆ្នាំមុន ២ ៣០០ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៥៦៧ ៨២៣ហ.ត ស្មើនឹង៩៨,០៣% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត តិចជាងឆ្នាំមុន ១៥៥ ៣០១ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៤៦០ ៧៨៨ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ១ ៨៧៥ ២៤៣តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,០៧០តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៤៦ ១៩១ហ.ត ស្មើនឹង៧៩,៧៨% នៃផែនការចំនួន ៥៧ ៩០០ហ.ត តិចជាងឆ្នាំមុន ៧ ៨៦៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៩០ ៤៧៦ហ.ត ស្មើនឹង១០១,៥៦% នៃផែនការចំនួន ៧៧៨ ៣០០ហ.ត លើសឆ្នាំមុន ១៣ ០៧៨ហ.ត។

## ១.៤ ការនាំចេញផលិតផលកសិកម្ម

### ១.៤.១ ការនាំចេញអង្ករ

បរិមាណការនាំចេញអង្កររយៈពេល៨ខែមានចំនួន ៣៨៩ ០០០តោន កើនឡើងចំនួន ៤៥ ៥៥៣តោន (១៣,២៦%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៨ខែឆ្នាំ២០២១ ដែលមានចំនួន ៣៤៣ ៤៤៧តោន ក្នុងនោះការនាំចេញអង្ករក្នុងខែសីហា ឆ្នាំ២០២២ មានចំនួន ៣៨ ០៩៨តោន កើនឡើងចំនួន ៤ ៥១៦តោន (១៣,៤៥%) បើធៀបនឹងខែសីហា ឆ្នាំ២០២១ ដែលមានចំនួន ៣៣ ៥៨២តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ២៥៩ ៨៨៧តោន ស្មើនឹង ៦៦,៨១% អង្ករសគ្រប់ប្រភេទមានចំនួន ១១៩ ៥៩៣តោន ស្មើនឹង ៣០,៧៤% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ៩ ៥២០តោន ស្មើនឹង ២,៤៥%។

បរិមាណអង្ករនាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២៣ប្រទេស មានបរិមាណសរុបចំនួន ១៣១ ៦៨០តោន (កើនឡើងចំនួន ៤៣ ៤០៩តោន ស្មើនឹង ៤៩,១៨%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៧៨ ១៤២តោន (កើនឡើងចំនួន ១២ ៥៣០តោន ស្មើនឹង ៧,៥៧%) ទិសដៅអាស៊ានចំនួន ៤ប្រទេស មានបរិមាណសរុបចំនួន ៣៤ ៦៣៣តោន (ថយចុះចំនួន ៩២០តោន ស្មើនឹង -២,៥៩%) និងទិសដៅដទៃទៀតចំនួន ២៥ប្រទេស មានបរិមាណសរុប ៤៤ ៥៤៥តោន (ថយចុះចំនួន ៩ ៤៦៦តោន ស្មើនឹង -១៧,៥៣%)។

ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៥៤ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ២៦៧ ៥១២តោន (៦៨,៧៧%) និងក្រុមហ៊ុន៤៤ដទៃទៀតបាននាំចេញត្រឹមតែ ១២១ ៤៨៨តោន (៣១,២៣%)។

### ១.៤.២ ការនាំចេញស្រូវ

ក្នុងរយៈពេល៨ខែឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ២ ២៦៩ ២១០តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ៥៥៨ ៣៥០តោន) មានការថយចុះចំនួន ១១៣ ៩៤០តោន (-៤,៧៨%) បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២១ មានចំនួន ២ ៣៨៣ ១៥០តោន។

### ១.៤.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងរយៈពេល៨ខែឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៤ ១៨២ ៧៥៦,៥៨តោន កើនឡើងចំនួន ៥៤៦ ២៦១,២២តោន ស្មើនឹង ១៥,០២% បើធៀបនឹងរយៈពេល៨ខែឆ្នាំ២០២១ មានចំនួន ៣ ៦៣៦ ៤៩៥,៣៦តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៦១២ ០៩០តោន (កើនឡើងចំនួន ២៥,៥៦%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ១៦៨ ៣០០តោន និងប្រទេសវៀតណាមចំនួន ៤៤៣ ៧៩០តោន
- ដំឡូងមីស្រស់មានចំនួន ៩៦០ ០៥០តោន (កើនឡើងចំនួន ១០៤,៥៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦០៩ ៨៥០តោន និងប្រទេសថៃចំនួន ៣៥០ ២០០តោន
- ម្សៅដំឡូងមីមានចំនួន ៥០ ៧៦៣តោន (កើនឡើងចំនួន ១៧១,៤៤%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៤៨ ៨៩៥តោន សហរដ្ឋអាមេរិកចំនួន ៦៦៦តោន ប្រទេសអ៊ីតាលីចំនួន ៥៦៥តោន ប្រទេសវៀតណាមចំនួន ២១០តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន ប្រទេសកាណាដាចំនួន ១០២តោន ប្រទេសថៃចំនួន ៩៨,៦០តោន ប្រទេសម៉ាឡេស៊ីចំនួន ៣៨,៤០តោន ប្រទេសសិង្ហបុរីចំនួន ១៩តោន និងប្រទេសឥណ្ឌាចំនួន ១៧តោន
- កាកសំណល់ដំឡូងមីមានចំនួន ៧ ៧៩១,៣៩តោន (កើនឡើងចំនួន ៣៧,៥៧%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៧ ២៩១,៣៩តោន និងប្រទេសវៀតណាមចំនួន ៥០០តោន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៤៦០ ៧៦៥,១៥តោន (ថយចុះចំនួន -៤៧,៣៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤៥៨ ៥៥១,២២តោន ប្រទេសថៃចំនួន ២ ០៥០តោន ប្រទេសឥណ្ឌាចំនួន ១៥០,១៦តោន ប្រទេសចិនចំនួន ១៣,៥៨តោន ប្រទេសជប៉ុនចំនួន ០,១៤តោន និងប្រទេសហ្វីលីពីនចំនួន ០,០៥តោន
- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ៤៩៣,៣៩តោន (ថយចុះចំនួន -៥២,៥៤%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ២២៦,០១តោន ប្រទេសចិនចំនួន ១៩៥,៦២តោន ប្រទេសជប៉ុនចំនួន ៤២,៥១តោន កោះតៃវ៉ាន់ចំនួន ២៤តោន និងប្រទេសកូរ៉េចំនួន ៥,២៥តោន
- គ្រាប់ពោតមានចំនួន ១៤២ ១៤៨,៩០តោន (ថយចុះចំនួន -៦,៦១%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៩៣ ២៩០តោន ប្រទេសថៃចំនួន ៤៨ ០០០តោន កោះតៃវ៉ាន់ចំនួន ៨៤៦,៦០តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន

- គ្រាប់សណ្តែកបាយមានចំនួន ៣៥ ០២៥,០១តោន (កើនឡើងចំនួន ៥០,៧៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៥ ០២៥តោន និងប្រទេសជប៉ុនចំនួន ០,០១តោន

- គ្រាប់សណ្តែកសៀងមានចំនួន ៧៦ ៤៨៥តោន (កើនឡើងចំនួន ២៨៤,៧៣%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៧០ ៦៣៥តោន និងប្រទេសថៃចំនួន ៥ ៨៥០តោន

- ផ្លែចេកស្រស់មានចំនួន ២៨០ ៧៥១,៣៩តោន (ថយចុះចំនួន -៩,៤៩%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២៥២ ៦៣៣,១៣តោន ប្រទេសវៀតណាមចំនួន ២៨ ១១៨,២១តោន និងប្រទេសជប៉ុនចំនួន ០,០៥តោន

- ផ្លែស្វាយស្រស់មានចំនួន ១២១ ២០១,៥៥តោន (ថយចុះចំនួន -២៦,០២%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦៤ ១៤០,២៣តោន ប្រទេសថៃចំនួន ២៩ ៤៣១,១២តោន ប្រទេសចិនចំនួន ២៧ ៤៦៧,៨៨តោន ប្រទេសកូរ៉េចំនួន ១៦០,០៨តោន និងទីក្រុងហុងកុងចំនួន ២,២៤តោន

- ដំណាប់ស្វាយមានចំនួន ១៤ ៣៤៦,៨០តោន (កើនឡើងចំនួន ១,៨៤%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១២ ៥៥៦,៩៥តោន ប្រទេសថៃចំនួន ៨៩៦,៥៣តោន ប្រទេសហ្វីលីពីនចំនួន ៤៩៩,៩៦តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសជប៉ុនចំនួន ៩៧,៣៤តោន ប្រទេសរុស្ស៊ីចំនួន ៧១,០៥តោន ប្រទេសអ៊ីតាលីចំនួន ១០,០៨តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសកូរ៉េចំនួន ៥,០៨តោន និងសហរដ្ឋអាមេរិកចំនួន ០,០៣តោន

- ដូងប្រេងមានចំនួន ៣៧ ៩៣៨,៧០តោន (កើនឡើងចំនួន ០,២៧%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ៣០ ៨៤៦,៧០តោន ប្រទេសម៉ាឡេស៊ីចំនួន ៦ ៩០០តោន និងប្រទេសថៃចំនួន ១៩២តោន

- ម្រេចមានចំនួន ៧ ៣៣៥,៦០តោន (ថយចុះចំនួន -៧០,៤៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦ ៤៦៧,៨៩តោន ប្រទេសអាល្លឺម៉ង់ចំនួន ៧៧៨,២០តោន កោះតៃវ៉ាន់ចំនួន ២១តោន ប្រទេសបារាំងចំនួន ១៦,៧៨តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១៣,២៤តោន សាធារណរដ្ឋឆែក ចំនួន ៩,៤៤តោន ប្រទេសកូរ៉េចំនួន ៤,៣៥តោន ប្រទេសជប៉ុនចំនួន ២,៩៨តោន ប្រទេសស៊ុយអ៊ែតចំនួន ២,៧៨តោន ប្រទេសកាណាដាចំនួន ១,២៨តោន សហរដ្ឋអាមេរិកចំនួន ០,៩២តោន ប្រទេសឥណ្ឌាចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសលីទុយអានីចំនួន ០,៤៥តោន ប្រទេសស្វីសចំនួន ០,៤០តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,២៥តោន ប្រទេសអូស្ត្រាលីចំនួន ០,១០តោន ប្រទេសរុស្ស៊ីចំនួន ០,០៣តោន និងប្រទេសណេដឺឡែនចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ៤ ៩៩១,៦៨តោន (កើនឡើងចំនួន ១៦២,៧៥%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤ ៨៨៩,៧០តោន កោះតៃវ៉ាន់ចំនួន ៤៧,២៥តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន ប្រទេសហ្វីលីពីនចំនួន ១៥,១១តោន និងប្រទេសអាហ្វ្រិកខាងត្បូងចំនួន ០,០២តោន

- បន្លែចម្រុះមានចំនួន ៦៣,៩៨តោន (ថយចុះចំនួន -៣,៨៣%) ក្នុងនោះនាំចេញទៅប្រទេសបារាំងចំនួន ៦៣,៩៤តោន និងប្រទេសនូវែលសេឡង់ចំនួន ០,០៤តោន

- ផលិតផលចំនួន ៨៩មុខ ផ្សេងទៀតមានចំនួន ៣៧០ ៥១៥,០៤តោន។

#### ១.៤.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ក្នុងរយៈពេល៨ខែឆ្នាំ២០២២ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ២ ៧០៨ ៨១១ ៣៩៥,៧៧ដុល្លារអាមេរិក ដែលក្នុងនោះ ៖

- ការនាំចេញអង្ករមានចំនួន ៣៣២ ៥៩៥ ០០០ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ៤៤៩ ៣០៣ ៥៨០ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ១ ៩២៦ ៩១២ ៨១៥,៧៧ដុល្លារអាមេរិក។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូខែកក្កដាសម្រេចបានចំនួន ៣០ ៤៩៨តោន កើនឡើងចំនួន ២៧៩តោន ស្មើនឹង១% ធៀបនឹងខែមុន និងថយចុះចំនួន ៩៦៨តោន ស្មើនឹង៣% ធៀបខែកក្កដា ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូខែកក្កដាសម្រេចបានចំនួន ៣ ៣៨៥ម³ កើនឡើងចំនួន ៥៤៧ម³ ស្មើនឹង១៦% ធៀបនឹងខែមុន។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូខែកក្កដាសម្រេចបានចំនួន ២៩ ៦២៥តោន ថយចុះចំនួន ៤៦៤តោន ស្មើនឹង ២% ធៀបនឹងខែមុន និងថយចុះចំនួន ១ ១៩០តោន ស្មើនឹង៤% ធៀបខែកក្កដា ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូខែកក្កដាសម្រេចបានចំនួន ២ ៩០២ម³ កើនឡើងចំនួន ៣៥៦ម³ ស្មើនឹង ១២% ធៀបនឹងខែមុន។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់ជ័រកៅស៊ូមធ្យមខែកក្កដា គឺ១ ៥១៥ដុល្លារ/តោន ថយចុះចំនួន ៥៧ដុល្លារ/តោន ស្មើនឹង៤% ធៀបនឹងខែមុន និងថយចុះចំនួន ៩២ដុល្លារ/តោន ស្មើនឹង៦% ធៀបខែកក្កដា ឆ្នាំ២០២១

- តម្លៃលក់ឈើកៅស៊ូមធ្យមខែកក្កដា គឺ១៥១ដុល្លារ/ម³

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារខែកក្កដា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៦៥០៛/គ.ក្រ ដល់ ៥ ៩៥០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៥០០៛/គ.ក្រ ដល់ ៣ ២០០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ ចំនួន ១០ផ្ទាំង

- ចុះកំណត់តំបន់សក្ដានុពលព្រៃសហគមន៍ចំនួន ២កន្លែង គឺព្រៃសហគមន៍ត្រពាំងប្រីយ៍មានផ្ទៃដីទំហំ១៨៥,៥១ហ.ត និងព្រៃសហគមន៍ព្រៃប៉ុស្ដិ៍មានផ្ទៃដីទំហំ១២២,៩១ហ.ត ស្ថិតនៅខេត្តកំពង់ធំ

- រៀបចំប្រជុំស្ដីពីការរៀបចំដីដាំដុះកសិ-រុក្ខកម្ម និងការគ្រប់គ្រងសហគមន៍ព្រៃឈើស្ថិតក្នុងសហគមន៍ព្រៃឈើ ចំនួន ១៤។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះប្រមូលសំណាកសត្វប្រចៀវ ជ្រឹងចំនួន ១លើក នៅខេត្តស្ទឹងត្រែង ដោយបានប្រមូលសំណាក (ឈាម ទឹកមាត់ លាមក ទឹកនោម និងចោះស្បែក) សត្វប្រចៀវសរុបចំនួន ៤៣០សំណាក។ សំណាក ទាំងនេះត្រូវបានយកមករក្សាទុកនៅវិទ្យាស្ថានជាតិអាឡែកហ្ស៊ី និងជំងឺឆ្លងរបស់សហរដ្ឋអាមេរិក សម្រាប់ការងារសិក្សាស្រាវជ្រាវស្វែងរកជំងឺដែលអាចបង្កហានិភ័យជំងឺឆ្លងមកដល់សត្វស្រុក និងមនុស្ស

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៦ច្បាប់ មានសត្វស្វាក្ដាមចំនួន ២ ៥២០ក្បាល សម្រាប់ដឹកជញ្ជូនទៅកាន់មាត់ច្រកអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង៩០០ក្បាលដឹកជញ្ជូនក្នុងស្រុក។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ៨ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្ដាមចំនួន ១៣៥ ៩០២ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៦ ៧៧៨ក្បាល

- កំពុងថែរក្សាសត្វព្រៃសរុបចំនួន ១ ៧៥៩ក្បាល សង្គ្រោះសត្វថ្មីចំនួន ៧៣ក្បាល ព្យាបាលសត្វព្រៃចំនួន ៤៦ក្បាល (បក្សី៥៩ប្រភេទ ថនិកសត្វ៤៥ប្រភេទ និងល្មូន១៦ប្រភេទ)

- ស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញចំនួន ១០១ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្ដារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ៤ ២៦០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ០,៣២ហ.ត។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៧៤៧ហ.ត ក្នុងនោះមានចម្ការពូជឈើទំហំ ៩៤ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហ.ត ចម្ការឈើដាំទំហំ ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ដាំឈើជាចម្ការថ្មីលើផ្ទៃដីទំហំ៦៥ហ.ត ក្នុងនោះនៅខេត្តកំពង់ធំទំហំ៤០ហ.ត និងខេត្តកំពង់ឆ្នាំងទំហំ ២៥ហ.ត។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ១១១ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ២៦ករណី និងសំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការចំនួន ៨៥ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងចំនួន ២១ម៣ ឈើអារចំនួន ១៤៥ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ៣៥ក្បាល និង៩៩គ.ក្រ ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ ៧០៩ហ.ត និងអនុផលព្រៃឈើមួយចំនួនទៀត

- វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ៤០ករណី ធ្វើកិច្ចសន្យាចំនួន ២ករណី ធ្វើការដកហូតចំនួន ១០ករណី រួមមាន សត្វព្រៃរស់ចម្រុះប្រភេទចំនួន ១៥៧ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទចំនួន ១ ២៩៦ក្បាល

- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃតាមរយៈការបង់ប្រាក់ពិន័យដោយតុលាការចំនួន ៥ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន១កន្លែង ស្ថិតនៅខេត្តកំពង់ធំ

- ក្រុមហ៊ុនចំនួន៣ នាំចេញផលិតផលរានទេវតាទៅក្រៅប្រទេសចំនួន ៣៣ម៣ ជ័រទឹកចំនួន ១៦តោន និងចំណាំងកម្ទេចឈើចំនួន ៤ ៥០០តោន

- ក្រុមហ៊ុនចំនួន២នាំចូលឈើកែច្នៃមានបរិមាណចំនួន ២១ម៣

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៥ មានឈើកែច្នៃចំនួន ២១០ម៣ ចំណាំងកម្ទេចឈើចំនួន ៤ ៥០០តោន និងជ័រទឹកចំនួន ១០៥តោន

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន២ មានឈើកែច្នៃចំនួន ៥៤២ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួនសរុប ១៣៣ ៩៤៩ ៨៣២រៀល និង៣៨ ៧៧៤,៦៣ដុល្លារ។

## ៤ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបចំនួន ១០ករណី ក្នុងនោះ ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ៦ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ៤ករណី (បទល្មើស)។ រាជធានី-ខេត្តចំនួន ២០បាននិងកំពុងអនុវត្ត

ជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៤ ៧៣៤លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វដល់កសិករ និងអ្នកពាក់ព័ន្ធក្នុងខេត្តចំនួន៣។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១៩ក្បាល។

- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ២ ៥១៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីសម្រេចបានត្រឹមខែសីហាចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៧ ៨០០តោន សរុបរយៈពេល៨ខែចំនួន ១២៩ ៥០០តោន ស្មើនឹង ៤៣,១៧%នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ៤៤ ៤០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៩ ២០០តោន សរុបរយៈពេល៨ខែចំនួន ៣៧ ០០០តោន ស្មើនឹង ២៦,៤៣%នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ កើនឡើងចំនួន ៧ ៥០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៩ ៩០០តោន សរុបរយៈពេល៨ខែចំនួន ៧៨ ៥០០តោន ស្មើនឹង៦០,៣៨% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ កើនឡើងចំនួន ១ ២០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២០ ៦០០តោន សរុបរយៈពេល៨ខែចំនួន ២២១ ៩០០តោន ស្មើនឹង ៦១,៦៤% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ កើនឡើងចំនួន ៧០ ៧៣១តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១៧ ៤០០ក្បាល សរុបរយៈពេល៨ខែចំនួន ៨៧ ៧០០ក្បាល ស្មើនឹង២៩,២៣% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ១១០ ១០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៣៣ ៥០០ ០០០កូន សរុបរយៈពេល៨ខែចំនួន ១២៣ ២០០ ០០០កូន ស្មើនឹង ៤១,០៧%នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ៣៥ ៥៤៨ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៧ ០០០តោន សរុបរយៈពេល៨ខែចំនួន ៣១ ៥០០តោន ស្មើនឹង៣៩,៣៨% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ៦ ៩៥០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ០០០តោន សរុបរយៈពេល៨ខែចំនួន ៧ ៨៦០តោន ស្មើនឹង៦៥,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ កើនឡើងចំនួន ៩០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ២ ៣០០ ០០០លីត្រ សរុបរយៈពេល៨ខែចំនួន ៣៨ ០៥០ ០០០លីត្រ ស្មើនឹង ៧៦,១០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ៤១២ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៨៤ករណី ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ២៤៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៧២ករណី និងសមុទ្រចំនួន ១២ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១៥២តោន សរុបរយៈពេល៨ខែចំនួន ២ ០៨៥តោន ស្មើនឹង២៦,០៦% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ៥៨២តោន

- ផលនេសាទកែច្នៃនាំចេញ សរុបរយៈពេល៨ខែចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ១០៩តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ៨ ២០០ ០០០រៀល សរុបរយៈពេល៨ខែចំនួន ៤៤២ ៨២៣ ៥០៣រៀល ស្មើនឹង១២៣,២៨% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបខែសីហា ឆ្នាំ២០២១ ថយចុះចំនួន ៥ ៦៦៨ ៩២៥រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចូលរួមប្រជុំពិភាក្សា និងស្តាប់របាយការណ៍ប្រចាំខែស្តីពីយុទ្ធនាការចុះបង្ក្រាបបទល្មើសជលផលនៅខេត្តសៀមរាប

- ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសជលផលនៅខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ឆ្នាំង

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១២៦ករណី លើវិស័យព្រៃឈើ៣៣ករណី ជលផល៥០ករណី សុខភាពសត្វនិងផលិតកម្មសត្វ១៣ករណី កៅស៊ូ១ករណី អគ្គនាយកដ្ឋានកសិកម្ម២ករណី និងវិស័យផ្សេងៗ២៧ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧៤៩ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៧៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣៣៩ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៣៧ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ១៦៣ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ២៦ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៣១ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែសីហា

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង (អន្តរនាយកដ្ឋាន) ចំនួន ៧លើក មានសមាជិកចូលរួមចំនួន ២៣៦នាក់ និងកិច្ចប្រជុំអន្តរក្រសួងចំនួន ២លើក មានសមាជិកចូលរួមចំនួន ៨៥នាក់

- ទទួលភ្ញៀវអន្តរជាតិចំនួន ៣លើក មានសមាជិកចូលរួមចំនួន ៤៥នាក់

- សិក្ខាសាលាចំនួន ៥លើក មានសមាជិកចូលរួមចំនួន ៨៩២នាក់

- សរុបការរៀបចំកិច្ចប្រជុំ និងការទទួលភ្ញៀវមានចំនួន ១៧លើក មានសមាជិកចូលរួមចំនួន ១ ២៥៨នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩៤៥នាក់ (ស្រី១ ៤៧៩នាក់ ស្មើនឹង២៤,៨៧%) រួមមានៈ
  + អង្គភាពថ្នាក់កណ្តាលចំនួន ៣ ០១៤នាក់ (ស្រី៨៧២នាក់ ស្មើនឹង២៨,៩៣%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៣១នាក់ (ស្រី៦០៧នាក់ ស្មើនឹង២០,៧០%)

- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៥នាក់ ទៅក្រៅក្រសួងចំនួន ១នាក់
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន ៦នាក់
- រៀបចំសំណើសុំដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍មុនកាលកំណត់ និងបោះពុម្ពសលាកបត្រមន្ត្រីរាជការស៊ីវិលចំនួន ៧នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២៤៩នាក់ (ស្រី៩៦នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២៣៥នាក់ (ស្រី៩៣នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ១៤នាក់ (ស្រី៣នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- ធ្វើលិខិតសំណើសុំទិន្នន័យសម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ (IDP) ក្នុងឆ្នាំ២០២១
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- រៀបចំ និងចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយសេវាព័ត៌មានទីផ្សារកសិកម្ម និងការប្រើប្រាស់កម្មវិធី CAM AgriMarket នៅខេត្តកំពត
- ចុះតាមដានការអនុវត្តផែនការលើអាជីវកម្មរបស់សហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យ
- ចូលរួមកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣
- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពថវិកាកម្មវិធីនៅខេត្តសៀមរាប
- បើកវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធតាមដាន និងវាយតម្លៃថវិកាកម្មវិធីចំនួន ៣វគ្គ នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តរតនគិរី។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៣ ៣០៦លានរៀល
- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៥ ៨៩៩លានរៀល
- ចូលរួមដេញថ្លៃឈ្នួលដាយត្រីលេញ និងដាយបង្កងសម្រាប់អាជីវកម្មក្នុងរដូវនេសាទឆ្នាំ២០២២-២០២៣ និងឆ្នាំ២០២៣-២០២៤ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង សាលារាជធានីភ្នំពេញ និងសាលាខេត្តកណ្តាល
- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន ៧ក្រុមហ៊ុន
- ចូលរួមអនុវត្តសកម្មភាពការងារក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ក្រោមគម្រោងហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃការដោះដូរទីតាំងដីមជ្ឈមណ្ឌលអភិវឌ្ឍន៍ពិពិធកម្មដំណាំកប់ស្រូវ ទីតាំងដីចម្ការឈើអង្គព្រលឹង និងទីតាំងដីនាយកដ្ឋានកសិឧ-ស្សាហកម្ម ដែលត្រូវដោះដូរជាមួយនឹងថ្នូររបស់ក្រុមហ៊ុន យុន សៀ អ៊ីមផត អិចផត។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ ធ្វើសំណើសុំជម្រះសម្ភារខូចខាតប្រើប្រាស់លែងកើត និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល
- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស

- ចុះធ្វើសវនកម្មចំនួន ១៦សវនដ្ឋាន ស្មើនឹង៤១,១០% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន៥០អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៩,៨៤% នៃផែនការចំនួន៥៦%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ធ្វើរបាយការណ៍កិច្ចប្រជុំផ្ទៃក្នុងស្តីពីសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការជំរុញការនាំចេញសំបុកត្រចៀកកាំពីកម្ពុជាទៅកាន់ប្រទេសចិន

- សម្របសម្រួលធ្វើលិខិតករណីសំណើបង់ក្លាដែសស្នើសុំរៀបចំកិច្ចប្រជុំរវាងគណៈប្រតិភូបង់ក្លាដែស ជាមួយក្រសួងពាក់ព័ន្ធកម្ពុជា អំពីការធ្វើកសិកម្មតាមកិច្ចសន្យា Contract Farming

- សម្របសម្រួលធ្វើលិខិតជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសំណើគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសពីរដ្ឋាភិបាលជប៉ុន សម្រាប់ឆ្នាំសារពើពន្ធ ២០២៣

- ចុះពិនិត្យទីតាំងត្រៀមរៀបចំ និងប្រារព្ធទិវាស្បៀងអាហារពិភពលោកឆ្នាំ២០២២

- សម្របសម្រួលធ្វើលិខិតទៅក្រសួងពាណិជ្ជកម្មករណីសំណើសុំផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរិមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៣ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៩ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ៨០សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនៅខេត្តកណ្តាល កំពង់ធំ និងខេត្តកំពត។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៧ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ចុះបណ្តុះបណ្តាលការប្រើប្រាស់ និងផ្សព្វផ្សាយអំពីកម្មវិធីស្មាតហ្វូន (Mobile App) គេហទំព័រ (Website) របស់បណ្ណាល័យកសិកម្ម និងពិនិត្យការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ និងខេត្តកែប

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បន្តចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកប្រាសាទបល្ល័ង្គ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្មនៅឃុំសាមគ្គី ខេត្តកំពង់ធំ

- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- ទទួលសៀវភៅឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីទទួលបានពីរដ្ឋបាល និងផ្នែកផ្សេងៗសរុបចំនួន ១១ក្បាល/ច្បាប់ ។

### ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះថត និងផលិត Video បទយកការណ៍ចំនួន ៧ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសំឡេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ៣៦ប្រធានបទ
- ផ្សព្វផ្សាយពី Video បច្ចេកទេសកសិកម្មចំនួន ៦៦Video ឯកសារជាអត្ថបទបច្ចេកទេសកសិកម្មចំនួន ៧២ឯកសារ
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ២២សំណួរ-ចម្លើយលើប្រធានបទបច្ចេកទេសចិញ្ចឹមមាន់ ទា គោ កង្កែប ដំឡូងមី ពោត ស្រូវ សណ្តែក ស្ពៃ ដំណាំម្ទេស និងដំណាំផ្សិត មកពីខេត្តពោធិ៍សាត់ ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ កណ្តាល កំពង់ចាម ស្វាយរៀង បន្ទាយមានជ័យ បាត់ដំបង ព្រៃវែង និងរាជធានីភ្នំពេញ។

### ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ១៩៤កិច្ចសន្យា គិតត្រឹមខែសីហា ឆ្នាំ២០២២ រួមមាន ខេត្តពោធិ៍សាត់ ៣៣កិច្ចសន្យា ស្ទឹងត្រែង៧កិច្ចសន្យា តាកែវ១៣កិច្ចសន្យា មណ្ឌលគិរី១កិច្ចសន្យា កំពង់ស្ពឺ២៨កិច្ចសន្យា កែប៤កិច្ចសន្យា កណ្តាល៨កិច្ចសន្យា ក្រចេះ១៤កិច្ចសន្យា ព្រះវិហារ១កិច្ចសន្យា ត្បូងឃ្មុំ២០កិច្ចសន្យា សៀមរាប១១កិច្ចសន្យា កំពង់ចាម ៤កិច្ចសន្យា ស្វាយរៀង៣កិច្ចសន្យា បន្ទាយមានជ័យ១៥កិច្ចសន្យា កំពង់ធំ៨កិច្ចសន្យា ប៉ៃលិន១២កិច្ចសន្យា និងខេត្ត កំពង់ឆ្នាំង១២កិច្ចសន្យា
- ចុះត្រួតពិនិត្យ និងកែសម្រួលចុងក្រោយលើឯកសារ ដើម្បីដាក់ស្នើសុំវិញ្ញាបនបត្រ HACCP និងត្រួតពិនិត្យ ដំណើរការអនុវត្តកែច្នៃគ្រាប់ស្វាយចន្ទីសរីរាង្គនៅខេត្តកំពង់ធំ
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ពាក់ព័ន្ធនឹងផលិតផលកសិកម្មតាម កិច្ចសន្យានៅខេត្តត្បូងឃ្មុំ
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តតាកែវ
- ចុះបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតកម្មកសិកម្មនៅខេត្តក្រចេះ។

### ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

#### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះត្រួតពិនិត្យសម្រាប់អនុវត្តសកម្មភាពនៃការចុះប៉ាន់ប្រមាណ និងវាយតម្លៃពូជស្វាយចន្ទីនៅខេត្តត្បូងឃ្មុំ សៀមរាប ឧត្តរមានជ័យ និងខេត្តព្រះវិហារ
- ចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រះវិហារ
- ចុះត្រួតពិនិត្យមើលការងារគ្រប់គ្រងទូទៅការងារពិសោធន៍ និងការងារផលិតកម្មគ្រាប់ពូជនៅស្ថានីយកោះកេរ្តិ៍ នៅខេត្តព្រះវិហារ
- ចុះរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសបំបៅកូនប៉េងប៉ោះ និងម្រេចនៅខេត្តកំពត
- ចុះប្រមូលទិន្នន័យកសិករស្តីអំពីការប្រើប្រាស់បច្ចេកទេសថ្មី និងកំណត់អំពីការផ្លាស់ប្តូរការអនុវត្តក្នុងផលិតកម្ម ដំណាំស្រូវនៅខេត្តត្បូងឃ្មុំ
- ចុះត្រួតពិនិត្យ ប្រមូលទិន្នន័យ និងដាក់ជីបំប៉នពិសោធន៍ដំឡូងមីនៅខេត្តព្រះវិហារ
- ចុះប្រមូលទិន្នន័យស្តីពីការយល់ដឹងពីជីជាតិដី និងការប្រើប្រាស់ជីលើដំណាំនៅខេត្តត្បូងឃ្មុំ
- ចុះរៀបចំការងារចម្ការពិសោធន៍បង្ហាញដំណាំសណ្តែកដីនៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ។

#### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រ ជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- ចុះអនុស្សរណៈយោគយល់រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុន ដាវណ្ណ ដើម្បីពង្រឹងការបណ្តុះ បណ្តាលធនធានមនុស្ស និងសុវត្ថិភាពអាហារ

- រៀបចំវគ្គបណ្តុះបណ្តាលអន្តរជាតិមួយស្តីពីការប្រែប្រួលការប្រើប្រាស់ដីក្នុងវិស័យកសិកម្ម និងព្រៃឈើ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រកម្ពុជា

- បើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើជីកំប៉ុស្ត និងប្រមូលសំណាកដី និងដំឡើងប្រព័ន្ធស្រោចស្រពសម្រាប់ពិសោធន៍នៅសហគមន៍កសិកម្មអាងកំពីងពួយ

- ជួបជាមួយតំណាងសភាពាណិជ្ជកម្មរបស់អាឡឺម៉ង់ ដើម្បីពិភាក្សាលើការគ្រប់គ្រងសំណល់ក្នុងការបំប្លែងទៅជាថាមពលអគ្គិសនីនៅកម្ពុជា និងចុះទៅត្រួតពិនិត្យដំណើរការប្រព័ន្ធចម្រោះជីវឧស្ម័ន និងដំណើរការម៉ាស៊ីនភ្លើងនៅកសិដ្ឋានចិញ្ចឹមជ្រូកនៅខេត្តសៀមរាប។

## ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ២៦២នាក់ (ស្រី៤៩៦នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងសៀងនិងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្មៅ អាហារ ថ្នាំសត្វល្អិត និងដី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

## ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្មក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- តាមដាន ស្រង់ វិភាគទិន្នន័យចម្ការពិសោធន៍ ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបចំនួន ៦២ពិសោធន៍

- ថែទាំកូនកៅស៊ូ Tissue Culture Plant ចំនួន ២៥០០កូន ដែលទទួលមកពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (RRI-CATAS)

- យកសំណាក និងវិភាគសរីរទឹកជ័រចម្ការកៅស៊ូក្នុងស្ថានីយពិសោធន៍បានចំនួន ៩២សំណាក

- អនុវត្តការងារថែទាំកូនកៅស៊ូគ្រប់ចម្ការពិសោធន៍

- បន្តអនុវត្តការងាររៀបចំថ្នាលបណ្តុះកូនកៅស៊ូសម្រាប់ឆ្នាំ២០២២-២០២៣

- អនុវត្តការងារមន្ទីរពិសោធន៍យថាប្រភេទកៅស៊ូតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017

- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) ចំនួន ៦សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR

- ចុះបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅសហគមន៍កសិកម្មស្ថិតក្នុងខេត្តត្បូងឃ្មុំ (សហគមន៍កសិកម្មសាមគ្គីកក់ សហគមន៍កសិកម្មពពេលមានជ័យ សហគមន៍កសិកម្មបែតងគោកស្រុក និងសហគមន៍កសិកម្មល្វៀងមានជ័យ)។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៥៦៧ ៨២៣ហ.ត ស្មើនឹង៩៨,០៣% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់

ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃ សុក្រ ១៤ កើត ខែ ស្រាពណ៍ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**